សលាកប័ត្រព័ត៌មាន៖ កម្រងឯកសារសេរីភាពមូលដ្ឋាន ៖ ការបំបិទសិទ្ធិផ្សព្វផ្សាយតាមរលកអាកាស
សេរីភាពមូលដ្ឋាន៖ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពខាងព័ត៌មាន
រូបភាពរួម៖ ការបំបិទសិទ្ធិផ្សព្វផ្សាយរបស់ប៉ុស្តិ៍វិទ្យុមួយចំនួនក្នុងពេលបោះឆ្នោតឃុំសង្កាត់ថ្មីៗនេះ បង្ហាញជាឧទាហរណ៍ អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ("រ.ដ.ក") ក្នុងគោលបំណងរារាំងប្រព័ន្ធផ្សព្វផ្សាយ និងដាក់កម្រិតលើសេរីភាពខាងព័ត៌មាន និងការបញ្ចេញមតិក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ដើម្បីរក្សាការគាំទ្រសន្លឹកឆ្នោត និងផ្នែកនយោបាយ ។ រ.ដ.ក បានបង្ហាញថាដំណើរការនេះនឹងត្រូវបានអនុវត្តន៍ម្តងទៀតនៅពេលបោះឆ្នោតជាតិក្នុងឆ្នាំ២០១៣ ។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ គូសបញ្ជាក់អំពីការដាក់កម្រិតលើសេរីភាពខាងព័ត៌មាន និងការបញ្ចេញមតិក្នុងប្រទេសកម្ពុជា ដោយបង្ហាញយ៉ាងច្បាស់តាមរយៈការហាមឃាត់ប្រតិបត្តិការប៉ុស្តិ៍វិទ្យុមួយចំនួនជាបណ្តោះអាសន្ន នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោតឃុំសង្កាត់ដែលកន្លងផុតទៅថ្មីៗនេះ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ។ សិទ្ធិសេរីភាពទាំងនេះតែងតែទទួលរងការគំរាមកំហែងក្នុងប្រទេសកម្ពុជា ទោះបីជាមានការការពារដោយច្បាប់ជាតិ អន្តរជាតិ និងរដ្ឋធម្មនុញ្ញក៏ដោយ ។ រ.ដ.ក តែងតែរារាំងប្រព័ន្ធផ្សព្វផ្សាយ តាមរយៈការបិទការបោះពុម្ពផ្សាយកាសែត គំរាមកំហែង និងផ្តន្ទាទោសអ្នកកាសែត ព្រមទាំងដាក់កម្រិតលើលទ្ធភាពទទួលបានការចាក់ផ្សាយតាមទូរទស្សន៍ ។ ការហាមឃាត់បែបនេះបញ្ជាក់ឲ្យឃើញថា រ.ដ.ក មានបំណងបន្តអនុវត្តន៍វិធីសាស្ត្រនេះមកលើប្រព័ន្ធផ្សព្វផ្សាយតាមរលកអាកាស ។ សលាកប័ត្រព័ត៌មាននេះតាក់តែងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា ដោយសហការជាមួយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ម.ក.ប.ឯ) ដែលជាអង្គការមិនមែនរដ្ឋាភិបាលដែលលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយដោយសេរី និងឯករាជ្យក្នុងប្រទេសកម្ពុជា ព្រមទាំងកម្មវិធីតាមរលកអាកាសដោយវិទ្យុសម្លេងប្រជាធិបតេយ្យ ("វីអូឌី") ។

ការបំបិទសិទ្ធិផ្សព្វផ្សាយតាមរលកអាកាស

នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ ក្រសួងព័ត៌មានបានទាក់ទងទៅស្ថានីយវិទ្យុមួយចំនួននៅកម្ពុជា ដើម្បីជូនដំណឹងដល់ពួកគេថា ស្ថានីយទាំងនោះត្រូវបានហាមឃាត់មិនឲ្យផ្សព្វផ្សាយកម្មវិធីដែលផលិតដោយវិទ្យុវីអូឌី អាស៊ីសេរី ("អរអេហ្វអេ") សំឡេងសហរដ្ឋអាមេរិក (វីអូអេ) វិទ្យុបារាំងអន្តរជាតិ និងវិទ្យុអូស្ត្រាលី ដែលជាកម្មវិធីផ្តល់នូវព័ត៌មានដែលមានគុណ្យភាព និងមិនលម្អៀងពីថ្ងៃទី០២ ដល់ទី ០៣ ខែមិថុនា ឆ្នាំ២០១២។ ការហាមឃាត់នេះ កើតឡើងស្របពេលជាមួយនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១២។ បន្ទាប់ពីការបោះឆ្នោត មន្ត្រីមកពីក្រសួងព័ត៌មាន បានការពារការហាមឃាត់ ដោយអះអាងថា ការហាមឃាត់នេះធ្វើឡើងដើម្បីរក្សានូវ "បរិយាកាសស្ងប់ស្ងាត់" ក្នុងអំឡុងពេលបោះឆ្នោត និងនិយាយថាការហាមឃាត់នេះធ្វើឡើងដោយស្របច្បាប់។ ប៉ុន្តែគ្មានភាពច្បាស់លាស់ថា តើការហាមឃាត់នេះផ្អែកលើមូលដ្ឋានច្បាប់មួយណានោះទេ ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ មន្ត្រីមកពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ("គ.ជ.ប") បានអះអាងថា គ.ជ.ប មិនបានដឹងអំពីការហាមឃាត់នេះទេ។ អាស៊ីសេរី វីអូអេ និងវីអូឌី បានសម្តែងការព្រួយបារម្ភចំពោះការហាមឃាត់នេះ និងសម្តែងនូវការិះគន់ទាក់ទិននឹងផលវិបាកនានាដែលកើតមានឡើងដោយសារតែការហាមឃាត់ក្នុងរយៈពេលពីរថ្ងៃដ៏សំខាន់នេះ។ អ្នកតំណាងរបស់ វីអូអេ ភាសាខ្មែរ បានប៉ាន់ប្រមាណថាការហាមឃាត់នេះបានបណ្តាលឲ្យប្រជាពលរដ្ឋរាប់រយពាន់នាក់ខកខានមិនបានស្តាប់ព័ត៌មាន ខណៈពេលដែលអាស៊ីសេរី បានចេញផ្សាយនូវសេចក្តីថ្លែងការណ៍ថា សេចក្តីសម្រេចលើការហាមឃាត់នូវការផ្សព្វផ្សាយនេះមានលក្ខណៈ "តាមទំនើងចិត្ត" និង "បង្កបញ្ហា" ។ ក្រុមប្រឹក្សាភិបាលនៃផ្សព្វផ្សាយ ដែលធ្វើការត្រួតពិនិត្យលើ អាស៊ីសេរី និង វីអូអេ បានថ្កោលទោសចំពោះការសម្រេចបែបនេះ ហើយបានហៅការហាមឃាត់នេះថា "ផ្ទុយនឹងគោលការណ៍ការបោះឆ្នោតដោយសេរី និងយុត្តិធម៌" ។

ខណៈពេលដែល រ.ដ.ក ជាទម្លាប់តែងតែត្រួតពិនិត្យយ៉ាងតឹងរឹងមកលើការផ្សព្វផ្សាយរបស់សារព័ត៌មាន និងស្ថានីយទូរទស្សន៍ខ្មែរ ប៉ុន្តែ វិទ្យុ និងអ៊ីនធើណែត ហាក់ដូចជានៅមានសេរីភាពច្រើនពីការគ្រប់គ្រង និងឥទ្ធិពលរបស់រដ្ឋាភិបាល ។ ទោះបីជាមានឧទាហរណ៍មួយចំនួន ដែលមានការត្រួតពិនិត្យមកលើវិទ្យុក្នុងអំឡុងពេលបោះឆ្នោតមុនៗ នេះគឺជាលើកដំបូងដែលរដ្ឋាភិបាលបានគ្រប់គ្រងវិទ្យុយ៉ាងទូលំទូលាយ ដែលបង្កឲ្យមានការព្រួយបារម្ភថា វិធានការទាំងនេះកំណត់ពីការចាប់ផ្តើមនិន្នាការថ្មីមួយក្នុងការគាបសង្កត់មកលើស្ថានីយវិទ្យុ ។ ការហាមឃាត់ដោយរដ្ឋាភិបាលបែបនេះ មិនត្រឹមតែបង្ហាញពីការកើនឡើងនៃឆន្ទៈរបស់រដ្ឋាភិបាលក្នុងការបង្កើនយុទ្ធសាស្ត្របែបនេះមកលើស្ថានីយវិទ្យុនោះទេ ហើយថែមទាំងប្រឆាំងនឹងច្បាប់ជាតិ និងអន្តរជាតិ ដើម្បីបង្ក្រាបសេរីភាពនៃការនិយាយស្តី និងការជជែកពិភាក្សា និងដើម្បីទទួលបានផលប្រយោជន៍ផ្នែកនយោបាយ៖ តាមរយៈការរឹតបន្តឹងកម្មវិធីរបស់ស្ថានីយវិទ្យុ ថាកម្មវិធីបែបណាទើបអាចអនុញ្ញាតឲ្យផ្សាយបាននៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ក្រុមប្រឹក្សាឃុំសង្កាត់ រ.ដ.ក មានបំណងចាត់វិធានការដើម្បីដាក់កំហិតទាំងលើសេរីភាពបញ្ចេញមតិ និងសេរីភាពខាងព័ត៌មាន (សូម

អានអត្ថបទខាងក្រោមសម្រាប់ព័ត៌មានបន្ថែម)។ ការហាមឃាត់បានកាត់បន្ថយសេរីភាពបញ្ចេញមតិមកលើអ្នកផលិតកម្មវិធីវិទ្យុ ដែលមិនអាចធ្វើការចាក់ផ្សាយនូវកម្មវិធីតាមការជ្រើសរើសរបស់ពួកគេ និងកម្មវិធីវិទ្យុដែលបានរៀបរាប់ខាងលើ ដែលត្រូវបានបំបិទទាំងស្រុង ។ ជាងនេះទៅទៀត ការហាមឃាត់នេះ ដាក់កម្រិតលើសេរីភាពខាងព័ត៌មាន មិនត្រឹមតែកំហិតនូវព័ត៌មានដែលស្ថានីយវិទ្យុអាចផ្តល់ទៅកាន់អ្នកស្តាប់នោះទេ ហើយថែមទាំងកំហិតលទ្ធភាពដែលអ្នកស្តាប់អាចស្វែងរក និងទទួលព័ត៌មានផងដែរ ។ ការហាមឃាត់នេះបាន ធ្វើឲ្យម្ចាស់ឆ្នោតនៅកម្ពុជា មិនអាចទទួលបាននូវព័ត៌មានដែលអាចរកបាន និងចាំបាច់សម្រាប់ការបោះឆ្នោត ។

សេរីភាពបញ្ចេញមតិ

សិទ្ធិសេរីភាពបញ្ចេញមតិ គឺត្រូវបានការពារដោយច្បាប់កម្ពុជា ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) បានចែងថា ពលរដ្ឋខ្មែរគ្រប់រូបមាន *“សិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពខាងព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការជួបប្រជុំ”* ។ មិនតែប៉ុណ្ណោះ មាត្រា៣៥ បានចែងថា ពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ ។ បន្ថែមពីលើនោះ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញចែងថាកម្ពុជាត្រូវទទួលស្គាល់ និងគោរពនូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដោយរួមបញ្ចូលសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងច្បាប់ជាតិ ចំណុចនេះត្រូវបានបញ្ជាក់បន្ថែមដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីខែកក្កដា ឆ្នាំ២០០៧ ដែលថារាល់លិខិតូបករណ៍សិទ្ធិមនុស្សដែលកម្ពុជាបានទទួលស្គាល់ គឺជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញ ។ មាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកតិកាសញ្ញានេះត្រូវបានកម្ពុជាទទួលស្គាល់ និងផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ចែងពីសិទ្ធិជាសកលនៃសេរីភាពបញ្ចេញមតិ ។

សេរីភាពខាងព័ត៌មាន

សេរីភាពខាងព័ត៌មាន ដែលសំដៅដល់ “សិទ្ធិយល់ដឹង” ឬក៏ “សិទ្ធិក្នុងការទទួលព័ត៌មាន” គឺត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ថាជាសិទ្ធិមនុស្សមូលដ្ឋាន និងមានទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់បានជាមួយនឹងសិទ្ធិដទៃទៀត។ ការទទួលបានព័ត៌មាន ក៏មានទំនាក់ទំនងជាមួយនឹងធាតុផ្សំមូលដ្ឋានដទៃទៀតនៃអភិបាលកិច្ចល្អ ដូចជា តម្លាភាព និងគណនេយ្យភាព និងមានសារៈសំខាន់ក្នុងការបង្កើតឲ្យមានទំនុកចិត្ត និងជំនឿចិត្តមកលើរដ្ឋាភិបាល ។ ប្រសិនបើគ្មានការទទួលបានព័ត៌មានទេ ប្រជាពលរដ្ឋនឹងត្រូវបានគេកាត់ផ្តាច់ចេញពីបញ្ហាដែលមានផលប៉ះពាល់ដោយផ្ទាល់មកលើជីវិតរស់នៅរបស់ពួកគេ ដូចជាគោលនយោបាយផ្សេងៗ ដែលគណបក្សនយោបាយនីមួយៗបានលើកឡើង ដែលជាមូលដ្ឋានសម្រាប់យុទ្ធនាការបោះឆ្នោតរបស់ពួកគេ ។ ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ សេរីភាពខាងព័ត៌មានគឺត្រូវបានការពារក្នុងផ្នែកមួយនៃសិទ្ធិសេរីភាពបញ្ចេញមតិ ដែលត្រូវបានការពារក្នុងមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលក្នុងកតិកាសញ្ញាបានចែងថា *“ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្វែរជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង [...] តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយតាមការជ្រើសរើសរបស់ខ្លួន”* ។ ខណៈពេលដែលនៅមិនទាន់មានច្បាប់ស្តីពីសេរីភាពខាងព័ត៌មានជាក់លាក់ណាមួយនៅកម្ពុជា សិទ្ធិនេះត្រូវបានការពារដោយច្បាប់ជាតិកម្ពុជា និងច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិ ។

សេចក្តីសន្និដ្ឋាន

រ.ដ.ក ត្រូវតែបញ្ចប់នូវសកម្មភាពរារាំងសិទ្ធិសេរីភាពបញ្ចេញមតិ និងសេរីភាពខាងព័ត៌មាន និងធានាថាសិទ្ធិមនុស្សជាមូលដ្ឋានទាំងនេះត្រូវបានគោរពគ្រប់ពេលវេលានៅកម្ពុជា ។ ការអនុវត្តន៍បែបនេះ ជះឥទ្ធិពលអវិជ្ជមានមកលើដំណើរការនៃលទ្ធិប្រជាធិបតេយ្យ ដោយដាក់កំហិតលើទំហំ និងភាពស៊ីជម្រៅនៃការពិភាក្សាស្តីពីបញ្ហាជាច្រើននៅកម្ពុជា ។ ម.ស.ម.ក បានជំរុញឲ្យរ.ដ.ក ចាត់វិធានការចាំបាច់មួយចំនួន ដើម្បីធានាថាសេរីភាពបញ្ចេញមតិ និងខាងព័ត៌មានត្រូវបានគោរពក្នុងគ្រប់កាលៈទេសៈ ហើយក្រសួងដែលពាក់ព័ន្ធត្រូវតែគោរពច្បាប់ និងបទដ្ឋានជាតិ និងអន្តរជាតិ ដែលការពារសិទ្ធិទាំងនេះ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង កញ្ញា សន រ៉ាមណា (+៨៥៥ (0) ១៧ ៦៥ ៥៥ ៩១ ឬអ៊ីម៉ែល៖ ramanasorn@cchrcambodia.org **ឬលោក រ៉ូប៊ឺត ហ្វីនច៍ (+៨៥៥ (0) ៧៨ ៨0 ៩៩ ៦0ឬអ៊ីម៉ែល៖** robert.finch@cchrcambodia.org**។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights